ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩

## សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន និងច្រានចោលសំណើសុំដោះលែង

នៅក្នុងសេចក្តីសម្រេចមួយនៅថ្ងៃនេះ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍ចំនួនពីររបស់ ខៀវ សំផន ប្រឆាំងនឹងដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេត គឺដីកាពន្យារពេលឃុំខ្លួនបណ្តោះអាសន្ននិងដីកាបដិសេធសំណើសុំដោះលែង។ ក្រោយពីមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ខៀវ សំផន អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នរហូតដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩។

ខៀវ សំផន ដែលកាន់តំណែងជាប្រមុខរដ្ឋ(ប្រធានគណៈប្រធានរដ្ឋ)ក្នុងអំឡុងរបបខ្មែរក្រហម ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម(សំណុំរឿងនេះកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត)។ គាត់ត្រូវបានចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាមួយបដិសេធសំណើសុំដោះលែងជនត្រូវចោទនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឲ្យពន្យារការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទរយៈពេលមួយឆ្នាំ។

នៅក្នុងសេចក្តីសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះសម្រេចថាការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ក្នុងការការពារសន្តិសុខរបស់ជនត្រូវចោទនិងរក្សាសណ្តាប់ធ្នាប់សាធារណៈ។

សេចក្តីសង្ខេបនៃសេចក្តីសម្រេចត្រូវបានអានដោយ **ឯកឧត្តម ប្រាក់ គឹមសាន** ប្រធានអង្គបុរេជំនុំជម្រះនៅក្នុងអំឡុងពេលសវនាការសាធារណៈនៅថ្ងៃនេះ។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរអាចរកមើល

បានលើគេហទំព័រ៖

http://www.eccc.gov.kh/English/cabinet/courtDoc/371/C26_5_26_Redacted_EN.pdf

រូបភាពផ្លូវការនៃសវនាការថ្ងៃនេះអាចទាញយកចេញពី៖

http://www.eccc.gov.kh/English/cabinet/photo/40/KSAMPHAN3July2009-3.jpg

http://www.eccc.gov.kh/English/cabinet/photo/40/KSAMPHAN3July2009-2.jpg

http://www.eccc.gov.kh/English/cabinet/photo/40/KSAMPHAN3July2009-1.jpg

ប្រព័ន្ធផ្សព្វផ្សាយអាចប្រើរូបភាពទាំងនេះដោយសេរីប៉ុន្តែគួរសរសេរថា៖ *"រូបភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"*


<u>សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖</u>

Lars Olsen

មន្ត្រីទំនាក់ទំនងច្បាប់ អ.វ.ត.ក

ទូរស័ព្ទចល័ត៖ +៨៥៥-១២ ៤៨៨ ០២៣

ទូរស័ព្ទអចល័ត៖ +៨៥៥-២៣ ២១៩ ៨១៤ ext.6169

អ៊ីមែល៖ olsenl@un.org

**ឌីម សុវណ្ណារុំ**

មន្ត្រីព័ត៌មាន អ.វ.ត.ក

ទូរស័ព្ទចល័ត៖ +៨៥៥-១២ ៤៨៨ ០៩៤

ទូរស័ព្ទអចល័ត៖ +៨៥៥-២៣ ២១៩ ៨១៤

អ៊ីមែល៖ dim.sovannarom@eccc.gov.kh